**មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម**
**THE CENTER FOR SOCIAL DEVELOPMENT**

# មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ធ្វើដំណើរឆ្ពោះទៅមុខជាមួយនឹង នាយិកាប្រតិបត្តិរបស់យើង

## សេចក្តីប្រកាសពត៌មាន

ភ្នំពេញ ៣០ មិថុនា ២០០៨: យើងខ្ញុំ សូមសំដែងនូវសេចក្តីកត្តញ្ញូដ៏ជ្រាលជ្រៅបំផុត ចំពោះអ្នកផ្តល់ជំនួយនានា ហើយជាពិសេសចំពោះជនរួមជាតិកម្ពុជាទាំងឡាយ ក្នុងការអត់ធ្មត់ និងការយល់ដឹងរបស់លោកអ្នក ក្នុងពេលនេះ ចំពោះការផ្ទុះបង្ហាញនូវការមិនជឿជាសាធារណ:ចំពោះមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (ម.អ.ស.), ដែលបានរាយការណ៍ដោយកាសែតភាសាអង់គ្លេសមួយ ជាមួយនឹងបុគ្គល៣នាក់ ដែលតាមពិត ត្រូវសហការ និងធ្វើការជាមួយយើងខ្ញុំ និងគាំទ្រការងារអភិវឌ្ឍន៍សង្គម ។ ម.អ.ស. មានវត្តមានគឺដោយសារ លោកអ្នកជាសាធារណជនកម្ពុជាទាំងអស់ ។ ម.អ.ស. ជារបស់លោកអ្នកទាំងអស់គ្នា ។ យើងខ្ញុំមានការសោកស្តាយដោយសារ “ការយករឿងផ្ទៃក្នុងរបស់ ម.អ.ស. ទៅដែកជាសាធារណ: ។ ដោយសារវាកើតឡើងរួចទៅហើយ ធ្វើអោយយើងខ្ញុំ មានកាតព្វកិច្ច ដើម្បីលាតត្រដាង ការយល់ច្រលំនានា និងការយល់ ឃើញខុសនានាក្នុងសេចក្តីប្រកាសខាងក្រោម៖

**១. ការបញ្ឈប់ការងារ មិនត្រឹមត្រូវតាមច្បាប់** ។ សារលិខិតនានាចុះថ្ងៃទី២១ ខែឧសភា (ប្រគល់ជូនដោយប្រើប្រាស់ខុសច្បាប់នូវកំលាំងនគរបាលក្រសួងមហាផ្ទៃ នៅពេលព្រឹកថ្ងៃបន្ទាប់) និងថ្ងៃទី២៣ខែមិថុនាឆ្នាំ២០០៨ ដើម្បីផ្តាច់កិច្ចសន្យាការងាររបស់នាយិកាប្រតិបត្តិ នៃ ម.អ.ស.ដោយមានការចុះហត្ថលេខាដោយលោក វី ហ៊ុយ, លោកស្រី ពឹង យក់ហៀប, និង លោកស្រី ជា វណ្ណាត, ក្នុងនាមជា “ក្រុមប្រឹក្សាភិបាល” គឺពុំមានប្រសិទ្ធភាព ឬ អំណាចច្បាប់ទាល់តែសោះ ។

<u>បើនិយាយអោយងាយយល់ទៅ, លោកស្រី ជា វណ្ណាត មិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ហើយរូបគាត់ ក៏មិនដែលធ្លាប់បានធ្វើ ជាសមាជិកក្រុមប្រឹក្សាភិបាលដែរ</u> ។ ក្រុមប្រឹក្សាភិបាលត្រូវការសមាជិកយ៉ាងហោចណាស់ចំនួនពី ៣ លើ ៥ នាក់ដើម្បីធ្វើការសំរេចចិត្ត ។ ដូច្នេះហើយ ទោះបីជា លោក វី ហ៊ុយ និងលោកស្រី ពឹង យក់ហៀប មានឋានៈបែបណាក៏ដោយក៏វាមិនមានសំលេងភាគច្រើនដែលអាចធ្វើអោយវិធានការទាំងនេះ មានភាពត្រឹមត្រូវតាមច្បាប់ឡើយ ។ ធម្មនុញ្ញ ម.អ.ស. បានចែងក្នុងមាត្រាទី៦ (ច) ថា: “ក្រុមប្រឹក្សាភិបាលនឹង<u>តែងតាំង</u>អ្នក ជំនួសសមរម្យណាម្នាក់...” (ឆ) ដែល “គណ:កម្មការគ្រប់គ្រងអាចផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាល ចំពោះការជំនួសតំណែងដ៏សមរម្យនេះ...” និង (ជ) ថា: “គណ:កម្មការគ្រប់គ្រង<u>និង</u>ក្រុមប្រឹក្សាភិបាលរួមសហការគ្នា ដើម្បីធានាថាតំណែងទំនេរណាមួយ នៃក្រុមប្រឹក្សាភិបាលត្រូវបំពេញ...”។ គណកម្មការគ្រប់គ្រងតែងតែធ្វើការបដិសេធ ដដែលជាដដែលយ៉ាងខ្លាំងក្លាលើសលប់ចំពោះការតែងតាំង លោកស្រី ជា វណ្ណាត ដូចមានក្នុងញ្ញត្តិ កាលពីខែវិច្ឆិកា ឆ្នាំ២០០៧ ដោយមានហត្ថលេខា៥១ ក្នុងចំណោមបុគ្គលិកទាំងអស់៥៤នាក់ ។

លើសពីនេះទៀត ភាពត្រឹមត្រូវតាមផ្លូវច្បាប់របស់ លោក វី ហ៊ុយ និងលោកស្រី ពឹង យក់ហៀប ជាសមាជិកក្រុមប្រឹក្សាភិបាល (ដែលកាលកំណត់អាណត្តិផុតត្រឹមខែវិច្ឆិកាឆ្នាំ ២០០៧នោះ) កំពុងស្ថិតក្នុងភាពមិនច្បាស់លាស់ ។ យោងតាមមាត្រាទី៦ (ង) សមាជិកក្រុមប្រឹក្សាភិបាល អាចបន្តអាណត្តិរបស់ខ្លួន រយៈពេល ២ឆ្នាំ បន្ថែមទៀត ។ ដោយឡែកមាត្រាទី ៦ (ឈ) ហាមឃាត់ក្រុមប្រឹក្សាភិបាលមិនអោយ *"ធ្វើការពិចារណា ឬអនុម័តលើសេចក្តីសំរេច ឬចេញសេចក្តីសំរេចណាមួយ ឬ អនុវត្តអំណាចខ្លួន រហូតដល់កំឡុងពេលនៃតំណែងទំនេរត្រូវបានបំពេញ..."* ។ ក្នុងខែវិច្ឆិកាឆ្នាំ២០០៧ នៅពេលដែលលោក វី ហ៊ុយ និងលោកស្រី ពឹង យក់ហៀប ហាក់អះអាង"បន្ត"អាណត្តិរបស់ខ្លួននោះ សមាជិក២រូបផ្សេងទៀតក្នុងក្រុមប្រឹក្សាភិបាលចំនួន៥នាក់តាមធម្មនុញ្ញបានលាលែងចេញពីតំណែង; ចំណែកឯតំណែងតំណាងបុគ្គលិក បានស្ថិតនៅទំនេរអស់រយៈពេលជិតមួយឆ្នាំ។ បើពិចារណាទៅលើតំណែងទំនេរទាំងនេះ វាមានភាពសង្ស័យ ថាតើការបន្តអាណត្តិទាំងនេះត្រឹមត្រូវតាមនីតិវិធីដែរឬទេ ។

**២. ការពិនិត្យឡើងវិញចំពោះស្ថាប័ន** ។ យោងទៅតាម ការពិនិត្យរៀបចំឡើងវិញចំពោះស្ថាប័ន, យើងបានទទួលការឧបត្ថម្ភពី អង្គការអុកស្វាមអាមេរិចកាំង (Oxfam America) ប្រសិនបើ ម.អ.ស. នឹងធ្វើកិច្ចការដើម្បីទាមទារនូវការទទួលខុសត្រូវក្នុងការងារឧស្សាហកម្មនីសារណកម្មនោះ ខ្លួនយើងនិងអង្គការទាំងមូលត្រូវមានមុខងារទទួលខុសត្រូវ (គំរោងនេះចាប់ពីខែកក្កដា២០០៧-មិថុនា២០០៨) ។ អស់រយៈកាល២ឆ្នាំកន្លងផុតទៅ (គឺចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៦មក) គំរោងការងារ ម.អ.ស. បានកើនឡើងទាំងទំហំនិងវិសាលភាព ( ឧទាហរណ៍ ការពង្រីកសាខាតាមបណ្តាខេត្ត, កម្មវិធីសំលេងយុត្តិធម៌ជាដើម), ថវិការសរុបកើនពី ៦០០,០០០ដុល្លា មក ៨០០,០០០ដុល្លាអាមេរិក, ចំណែកបុគ្គលិកកើនពីចំនួន ២៨ នាក់ មកជិត៨០ នាក់ ។ ការរីកចំរើនដ៏គំហុកនេះ ធ្វើអោយមានភាពតានតឹងចំពោះប្រពន្ធ័ទាំងឡាយ និង និតិវិធីនានារបស់អង្គការ ។ ដូច្នេះ ការពិនិត្យមើលឡើងវិញចំពោះអង្គការបានផ្តល់ឱកាសសំរាប់ ម.អ.ស. ដើម្បីពង្រឹង ចំពោះទិសដៅដែលខ្លួនឆ្ពោះទៅ និងកំណត់មាគ៌ានានាដើម្បីពង្រឹងប្រសិទ្ធភាពអង្គការតាមរយៈ (១) ពង្រឹងរចនាសម្ពន្ធ័គ្រប់គ្រងនិងដំណើរការនានា, (២) ពង្រឹងកម្មវិធីនិងប្រតិបត្តិការគ្រប់គ្រង ។ ជាពិសេសរឿងបន្ទាន់ចំបង ដោយសារការរីកលូតលាស់ឆាប់រហ័សនេះបានធ្វើឡើងដោយគ្មានក្រុមប្រឹក្សាភិបាលអស់រយៈកាលជាង ១ឆ្នាំ, និងកំឡុងពេលមានភាពតានតឹង រវាងក្រុមប្រឹក្សាភិបាលបច្ចុប្បន្ន និងបុគ្គលិក ម.អ.ស./គណកម្មការគ្រប់គ្រង, ការកើតឡើងដោយភាពមិនច្បាស់លាស់/មិនប្រាកដនៃតួនាទី និងការទទួលខុសត្រូវ ។ មនុស្សគ្រប់រូបជឿថា រឿងដំបូងដែលត្រូវធ្វើនោះគឺ ការអនុម័តវិសោធនកម្មពង្រាងធម្មនុញ្ញ (ដើម្បីជំនួសធម្មនុញ្ញចាស់ដែលពុំមានរចនាសម្ព័ន្ធទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងភាពច្បាស់លាស់), កិច្ចការនេះ ត្រូវបន្តធ្វើដោយមានការពិភាក្សានានា និងការសំរេចចិត្ត ក្នុងការជ្រើសយករចនាសម្ព័ន្ធគ្រប់គ្រងប្រសើរជាង រចនាសម្ពន្ធ័ "បែបរាបស្មើ" បច្ចុប្បន្ន ដែលលែងបំរើសេចក្តីត្រូវការនៃសមត្ថភាព និងប្រសិទ្ធភាពរបស់ ម.អ.ស. ទៀតហើយនោះ ។

៣. **បុគ្គលិកគាំទ្រយ៉ាងលើសលប់ចំពោះនាយិកាប្រតិបត្តិ** ។ ម.អ.ស.ទទួលបានជោគជ័យនូវការសំរេចបានគោលដៅរបស់យើង និងបេសកកម្មដោយសារ យើងមានក្រុមដ៏ឆ្នើម មានវ័យក្មេង, ឧស្សាហ៍ព្យាយាម, ស្វាហាប់, មានចិត្ត, ពួកគេចង់បានយ៉ាងខ្លាំងនូវសង្គមដែលមានភាពប្រសើរជាងមុន ហើយពួកគេកំពុងពុះពារដើម្បីសំរេចបំណងនេះ ។ យើងខ្ញុំមិនត្រឹមតែជាក្រុមដែល "និយាយ" អំពីភាពជាម្ចាស់, ការដឹកនាំ, ធ្វើជាគំរូនោះទេ, ប៉ុន្តែយើងអនុវត្តភារកិច្ចទាំងនោះ ។ ក្រុម ម.អ.ស នេះដឹកនាំដោយនាយិកាប្រតិបត្តិរបស់យើង គឺ កញ្ញា សេង ធារី ដែលមានការគាំទ្រពីបុគ្គលិកជិត៨០នាក់ (បុគ្គលិកជាង ៧០ នាក់, ក្នុងនោះ ១១ ក្នុងចំណោម ១២នាក់ ជាគណៈកម្មការគ្រប់គ្រង) ។

៤. **ម.អ.ស. ធ្វើដំណើរឆ្ពោះទៅមុខ** ។ យើងយល់ថា សមាជិកក្រុមប្រឹក្សាភិបាល ១១ នាក់ថ្មី ពុំបានដឹងរឿងច្បាស់ មិនរំពឹងថាអាចមកប្រឈមមុខជាមួយនឹងរឿងវិវាទផ្ទៃក្នុងទាំងអស់នេះបានទេ ។ ដោយសារមានសកម្មភាពបំផ្លិចបំផ្លាញថ្មីៗនេះតាមមធ្យោបាយសាធារណៈ យើងខ្ញុំបានលប់ចោលការប្រជុំសំខាន់ៗជាច្រើនដើម្បីអោយខួរក្បាលនិងខ្លួនយើងបានស្ងប់, មានការយល់ដឹងបន្ថែមទៀតក្នុងចំណោមភាគីពាក់ពន្ធ័នានា, និងទុកពេលវេលានេះ ក្នុងការរិះគិត និងរិះរកជំរើសនានាជាសក្តានុពលឆ្លើយតប ។ យើងខ្ញុំមានជំនឿថា យើងនឹងងើបចេញផុតពីដំណាក់កាលនេះ ដោយធ្វើអោយអង្គការនេះមានភាពរឹងមាំ និងមានការបំពេញមុខងារប្រសើរជាងមុនប្រកបដោយភាពចាស់ទុំ, ឧស្សាហ៍ព្យាយាម, មានបុគ្គលិកប្រកបដោយប្រាជ្ញាវាងវៃនិងមានការទទួលខុសត្រូវ ។ យើងមិនអោនទទួលយកអំពើឃោរឃៅ, ការប្រើកំលាំង និង ភាពអយុត្តិធម៌, ឬស្ថិតជាប់ក្នុងផ្នត់គំនិតបំបែកបំបាក់នេះបានទេ ។ យើងតែងតែរំលឹកគ្នាទៅវិញទៅមកថា "ការប្រឈមជាឱកាស ឬ ជាពរជ័យដោយមិនដឹងខ្លួន" ។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះការអត់ធ្មត់របស់លោកអ្នក, ការយល់ដឹងនិងសំដែងចេញការគាំទ្រចំពោះយើងខ្ញុំនៅ ម.អ.ស. ។

***ចំពោះព័ត៌មានបន្ថែម សូមទាក់ទង:***


- *កញ្ញា សេង ធារី* នាយិកាប្រតិបត្តិ, ជាសមាជិកគណៈកម្មការគ្រប់គ្រង ០១២ ២២២ ៥៥២
- *លោក អ៊ឹម សុភា* ជំនួយការប្រតិបត្តិ, ជាសមាជិកគណៈកម្មការគ្រប់គ្រង ០១២ ៧៨៧ ៦៧៩
- *កញ្ញា ប៉ែន រ៉ានី* ប្រធានអង្គភាពច្បាប់,ជាសមាជិកគណៈកម្មការគ្រប់គ្រង ០១២ ៧០២ ៧៦៣
- *លោក សឿង ចន្ទ័តារា* ប្រធានអង្គភាពហិរញ្ញវត្ថុ, ជាសមាជិកគណៈកម្មការគ្រប់គ្រង ០១២ ៧៧៧ ០៧៧
- *លោកស្រី ជួ វិនាដ* ប្រធានកម្មវិធីសង្កេតការណ៍តុលាការ, ជាសមាជិកគណៈកម្មការគ្រប់គ្រង ០១២ ៥៥៤ ៨២៨
- *លោក តុង ហេង* អនុប្រធានកម្មវិធីសង្កេតការណ៍តុលាការ ០១៦ ៨៤៨ ៦៤៦
- *លោក ស៊ិន គីណាល់* អ្នកសំរបសំរួលគំរោងពលរដ្ឋឃ្លាំមើលសិទ្ធិ ០១៦ ៣២១ ៧៦៦
- *បណ្ឌិត អ៊ឹម ហ្វ្រង់ស្វ័រ* ប្រធានអង្គភាពឃ្លាំមើលសភានិងបោះឆ្នោត ០១២ ៣៧៦ ៣០១
- *លោក ប៉ាយ ចាន់ថន* ប្រធានផ្នែកព័ត៌មានវិទ្យា, ថ្មីៗនេះត្រូវបានបោះឆ្នោតជ្រើសតាំងជាតំណាងបុគ្គលិកនៅក្នុងក្រុមប្រឹក្សាភិបាល ០១២ ៩៥៩ ០២០

- *លោក ឌួង សាវ៉ន* អ្នកសំរបសំរួលផ្សព្វផ្សាយភាពយន្ត ០១២ ៨០០ ៨១៦
- *លោក សុខ លាំង* ជំនួយការជាន់ខ្ពស់នៃអង្គភាពវេទិកាសាធារណៈ ០១២ ៥៨៨ ០៨១
- *លោក ហាក់ សុខលៀប* អ្នកសំរបសំរួលគំរោង “អាយរីដ” ០១២ ៨៣១ ២៦៤